ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពុទ្ធមណ្ឌលវិបស្សនាធុរៈ
នៃព្រះរាជាណាចក្រកម្ពុជា

# ទីឃីតិកោសលជាតក
## ( រៀនរឿងម្ចាស់ដោយការមិនចងពៀរ )

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់គង់ប្រថាប់នៅនាងមហាវិហារព្រះជេតពន ទ្រង់ប្រារព្ធពួកភិក្ខុក្រុង កោសម្ពីដែលឈ្លោះទាស់ទែងគ្នា ទើបព្រះអង្គត្រាស់សម្ដែងនូវព្រះធម៌ទេសនានេះ ដោយពាក្យថា **ឯវំ ភូតស្ស តេ រាជ**ដូច្នេះជាដើម ។

បានស្ដាប់មកថា ក្នុងកាលដែលភិក្ខុទាំងនោះ និមន្តមកកាន់ព្រះជេតពនមហាវិហារ ដើម្បីសូមនូវការអត់ទោសពី ព្រះបរមសាស្តា ព្រះដ៏មានព្រះភាគ ត្រាស់ហៅភិក្ខុទាំងនោះមកហើយ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ជាឱរសរបស់តថាគត គឺជាកូនដែលកើតអំពីមាត់ ។ ធម្មតាដែលជាឱរស គឺមិនគួរទម្លាយនូវឱវាទ ដែលបិតាទុកឲ្យហើយ ប៉ុន្តែអ្នកទាំងឡាយ បែរទៅជាអ្នកមិនធ្វើតាមឱវាទរបស់តថាគត គឺជាអ្នកទម្លាយនូវឱវាទ ទៅវិញ ។ បណ្ឌិតទាំងឡាយពីបុរាណ សូម្បីចោរដែលជាអ្នកសម្លាប់មាតាបិតារបស់ខ្លួន ហើយប្លន់យកនូវ រាជសម្បត្តិ បានធ្លាក់ចូលក្នុងកណ្ដាប់ដៃក្នុងព្រៃ ក៏នៅតែឲ្យអភ័យ មិនសងសឹក ដោយគិតថា យើងនឹងមិន ទម្លាយឱវាទដែលមាតាបិតាទុកឲ្យ ។ រួចហើយ ព្រះអង្គទ្រង់នាំយករឿងក្នុងអតីតកាលមកសម្ដែង ។ រឿងដោយពិស្ដារមានក្នុងវិនយបិដក រឿងដោយសង្ខេបមានដូចតទៅ ៖

ក្នុងអតីតកាល ស្ដេចក្រុងពារាណសីទ្រង់ព្រះនាមព្រហ្មទត្ត ជាស្ដេចស្ដុកស្ដម្ភមាំមួន បានលើកទ័ពចេញទៅច្បាំង នឹងស្ដេចទីឃីតិកោសល ។ ស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិ ជាស្ដេចកម្សត់មានសម្បត្តិតិច មានកម្លាំងទ័ព តិច បាននាំមហេសីលបរត់ចេញពីក្រុងជាមុន ។ គ្រានោះ ស្ដេចក្នុងដែនកាសិព្រះនាមព្រហ្មទត្ត បានដណ្ដើមយក ពួកពល ពាហនៈ ជនបទ ឃ្លាំង ជង្រុករបស់ស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិ ហើយគ្រប់គ្រងរក្សា ។ ចំណែកស្ដេចទីឃីតិបាននាំមហេសីទៅអាស្រ័យនៅក្នុងផ្ទះស្មូនឆ្នាំង ដែលឋិតនៅជាយក្រុងពារាណសី ដោយក្លែង ភេទមិនឲ្យអ្នកដទៃស្គាល់បាន ទ្រង់ស្លៀកដណ្ដប់ជាបរិញ្វាជក ។ ក្រោយមកមិនយូរប៉ុន្មាន ព្រះមហេសីនៃព្រះ បាទទីឃីតិក៏ទ្រង់គភ៌ លុះដល់គភ៌ចាស់ហើយ ក៏បានប្រសូតនូវព្រះបរមពោធិសត្វ ព្រះមាតាបិតាទ្រង់ប្រទាននាម ថា ទីឃាវុ ។ លុះដល់ទីឃាវុកុមារដឹងក្ដី បិតាក៏បញ្ជូនបុត្រឲ្យទៅនៅក្រៅក្រុង ក្រែងថ្ងៃមុខថ្ងៃក្រោយ ស្ដេចដែន កាសីជ្រាប ដំណឹងនឹងសម្លាប់ទាំងអស់គ្នា ។ ទីឃាវុកុមារ កាលដែលនៅក្រៅក្រុង មិនយូរប៉ុន្មានក៏បានសិក្សាចេះដឹងនូវសិល្បសាស្ត្រសព្វគ្រប់ ។

ពិតមែន ដោយមានអ្នកក្រាបទូលដល់ព្រះបាទព្រហ្មទត្តជាស្ដេចដែនកាសី ព្រះបាទទីឃីតិនិង

ព្រះអគ្គមហេសី ក៏ ត្រូវចាប់ខ្លួនបាន គេចងដើមដៃទ្រង់ទាំង ២ ព្រះអង្គទៅខាងក្រោយដោយចំណងដ៏មាំ កោរក្បាលឲ្យរលីង ទូង ស្គរបណ្ដើរសព្វច្រក សព្វផ្លូវត្រឡែងកែង ។ កាលនោះ ទីឃាវុកុមារមានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញខាន ឃើញមាតាបិតាយូរណាស់ហើយ បើដូច្នោះគួរតែអាត្មាអញទៅមើលមាតាបិតាបានម្ដងសិន ។ ទីឃាវុកុមារ ចូល ទៅដល់ក្រុងពារាណសីហើយ បានឃើញមាតាបិតាដែលគេកំពុងតែចងស្លាបសេកបណ្ដើរគ្រប់ច្រកល្ហក និងគ្រប់ ផ្លូវ លុះឃើញហើយ ក៏ចូលទៅរកមាតាបិតា ។ ព្រះបាទទីឃីតិ ទ្រង់ទតឃើញបុត្រមកអំពីចម្ងាយ ក៏ស្រែកផ្ដាំបុត្រ ដូច្នេះថា នែទីឃាវុកូន ! ចូរកូនកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ! ធម្មតាពៀរមិនដែលរម្ងាប់ដោយ ការចងពៀរទេ គឺពៀរតែងរម្ងាប់ដោយការមិនចងពៀរ ។ ពួកជនទាំងឡាយ បានសម្គាល់ព្រះអង្គថាឆ្កួតវង្វេងវាយ និយាយផ្ដេសផ្ដាស ហើយបាននាំព្រះអង្គចេញទៅតាមទ្វារខាងត្បូង កាត់ខ្លួនព្រះអង្គជា ៤ កំណាត់ ។ លុះដល់ ពេលស្ងាត់ ព្រះបរមពោធិសត្វទីឃាវុកុមារ ក៏បានចូលដល់ទីប្រហារជីវិត ប្រមូលកំណាត់ឈើហើយលើកសរីរៈ មាតាបិតាដាក់លើជើងថ្ករ រួចក៏បូជាដោយភ្លើង ផ្គងអញ្ជលីធ្វើប្រទក្សិណជើងថ្ករ ៣ ជុំ ។ គ្រានោះ ទីឃាវុកុមារទៅ ឯព្រៃ ហើយខ្សឹកខ្សួលទួញយំ ដោយសេចក្ដីអាល័យអួលណែនក្នុងទ្រូង យំអស់ចិត្តហើយទើបជូតទឹកភ្នែក ត្រឡប់ចូលក្រុងពារាណសីវិញ ទៅសូមរៀនសិល្បៈនឹងហ្មដំរី នៅជិតព្រះរាជវាំង ។ ទីឃាវុកុមារ ក្រោកឡើងក្នុង បច្ចូសសម័យនៃរាត្រី ស្រែកច្រៀងដោយសំឡេងដ៏ពីរោះ ព្រមទាំងដេញពិណផងក្នុងរោងដំរី ដែលធ្វើឲ្យព្រះរាជាពេញព្រះរាជហឫទ័យ ឲ្យនៅបម្រើព្រះអង្គ ។ ដោយទីឃាវុកុមារពូកែផ្គាប់ចិត្តព្រះរាជា មិនយូរប៉ុន្មានព្រះរាជាក៏បានតែងតាំងទីឃាវុកុមារ ក្នុងភាពជាអ្នកសិទ្ធស្នាលខាងក្នុង ។

ថ្ងៃមួយព្រះរាជា បានត្រាស់បង្គាប់ឲ្យទីឃាវុកុមារទឹមរាជរថ នាំព្រះអង្គទៅប្រពាតម្រឹគក្នុងព្រៃ ។ ព្រះរាជានឿយ ហត់ព្រះកាយដោយផ្លូវឆ្ងាយបានត្រាស់ឲ្យទីឃាវុកុមារដាក់រាជរថសិន ហើយផ្ទំកើយព្រះសីសៈលើភ្លៅទីឃាវុកុមារ ក្រោមម្លប់ឈើ ក៏លង់លក់មួយរំពេចទៅ ។ លំដាប់នោះ ទីឃាវុកុមារ ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា ស្ដេចក្នុង ដែនកាសីព្រះនាមព្រហ្មទត្តនេះ បានធ្វើនូវសេចក្ដីវិនាសជាច្រើនដល់អាត្មាអញ ទាំងពលពាហនៈ ជនបទ ឃ្លាំង និង ជង្រុក របស់អាត្មាអញ ស្ដេចនេះរឹបជាន់យកអស់ មិនតែប៉ុណ្ណោះ ទាំងមាតាបិតារបស់អាត្មាអញ ក៏ត្រូវស្ដេច នេះសម្លាប់ចោលអស់ទៀត វេលានេះ គួរអាត្មាអញសងពៀរដល់ស្ដេចនេះវិញ ហើយក៏ហូតព្រះខាន់ចេញពី ស្រោម ។ វេលានោះ ទីឃាវុកុមារមានសេចក្ដិត្រិះរិះយ៉ាងនេះថា បិតាបានផ្ដាំអាត្មាអញក្នុងពេលដែលទៀបនឹង ធ្វើមរណភាពថា នែទីឃាវុកូន អ្នកឯង កុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតាពៀរមិនដែលរំងាប់ ដោយការចងពៀរទេ គឺពៀរតែងរំងាប់ដោយការមិនចងពៀរ បើអាត្មាអញកន្លងពាក្យបិតាហើយ អំពើនេះឈ្មោះ ថា មិនសមគួរដល់អាត្មាអញឡើយ ហើយក៏សៀតព្រះខាន់ចូលទៅក្នុងស្រោមវិញ ។ ទីឃាវុកុមារ មានសេចក្ដីត្រិះរិះឃើញការសងពៀរ ជាលើកទី ២ និងជាលើកទី ៣ ប៉ុន្តែរាល់លើកមិនបានសម្រេចឡើយ ដោយរលឹកឃើញ បណ្ដាំព្រះបិតាមុននឹងគេធ្វើឃាតព្រះអង្គ ។ គ្រានោះ ស្ដេចព្រហ្មទត្តទ្រង់ភិតភ័យភ្ញាក់ផ្អើលស្ទើតស្លក់តក់ស្លុត ហើយក៏តើនឡើងភ្លាម ។ ទីឃាវុកុមារ ទូលសួរដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស

ហេតុអ្វីបានជាព្រះអង្គទ្រង់ ភិតភ័យតក់ស្លុត ហើយតើនឡើងដូច្នេះ ? ស្ដេចក៏តបថា នែនាយមាណព ព្រោះយើងយល់សប្តិ ឃើញដូចជា ទីឃាវុកុមារ ជាកូនស្តេចក្នុងដែនកោសល ឈ្មោះទីឃីតិ លើកព្រះខាន់ឡើងគំរាមយើងក្នុងទីនេះ ព្រោះហេតុ នោះ បានជាយើងភ័យភ្ញាក់ផ្អើល ស្លើតស្លក់តក់ស្លុត ហើយក្រោកឡើងភ្លាម ។ ភ្លាមនោះ ទីឃាវុកុមារ បានយកដៃ ខាងឆ្វេងចាប់សង្កត់ព្រះសីសៈនៃស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ហើយយកដៃខាងស្តាំហូតព្រះខាន់ រួច និយាយពាក្យនេះនឹងស្ដេចថា នែព្រះអង្គ ! ទូលព្រះបង្គំនេះហើយ ដែលឈ្មោះទីឃាវុកុមារ ជាកូនស្ដេចក្នុងដែន កោសលព្រះនាមទីឃីតិ ព្រះអង្គបានធ្វើសេចក្តីវិនាសជាច្រើនដល់ទូលព្រះបង្គំ ទាំងព្រះមាតាបិតារបស់ទូលព្រះ បង្គំ ព្រះអង្គក៏ឲ្យគេធ្វើឃាតចោលទាំងអស់ ពេលនេះ គួរតែទូលព្រះបង្គំសងពៀរដល់ព្រះអង្គវិញ ។ ទីឃាវុកុមារ គិតថា យើងនេះសូម្បីត្រូវលះបង់ជីវិត ក៏មិនទម្លាយនូវឱវាទព្រះបិតាយើងឡើយ គ្រាន់តែសម្លុតព្រះរាជាប៉ុណ្ណោះទើបពោលគាថាដែលមានសេចក្តីថា ៖

បពិត្រព្រះរាជា ព្រះអង្គធ្លាក់មកក្នុងអំណាចរបស់ទូលព្រះបង្គំ យ៉ាងនេះហើយ តើហេតុណាមួយដែលញ៉ាំងព្រះ អង្គឲ្យរួចចាកទុក្ខ មានដែរឬ ?

ព្រះរាជាត្រាស់នូវព្រះគាថាឆ្លើយតប ដែលមានសេចក្តីថា ៖

ម្នាលអ្នកអើយ យើងធ្លាក់នៅក្នុងអំណាចរបស់អ្នក ប្រាកដយ៉ាងនេះហើយ ហេតុណាមួយដែលញ៉ាំងយើងឲ្យរួច ចាកទុក្ខ មិនមានឡើយ ។

វេលានោះស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ក៏ឱនព្រះសិរក្រាបទៀបជើងទីឃាវុកុមារហើយមានព្រះរាជឱង្ការ ទៅនឹងទីឃាវុកុមារយ៉ាងនេះថា នែទីឃាវុកូន ! សូមអ្នកអាណិតឲ្យជីវិតដល់យើងផងនែទីឃាវុកូន ! សូមអ្នក អាណិតឲ្យជីវិតដល់យើងផង ។ ទីឃាវុកុមារតបវិញថា ទូលព្រះបង្គំនឹងថ្វាយជីវិតព្រះអង្គដូចម្ដេចទៅ គឺគួរតែ ព្រះអង្គប្រទានជីវិតទូលព្រះបង្គំទៅវិញទេ ។ ព្រះរាជាត្រាស់ថា នែទីឃាវុកូន ! បើដូច្នោះអ្នកចូរឲ្យជីវិតយើងចុះ ឯយើងក៏ឲ្យជីវិតអ្នកវិញដែរ ។

កាលដែលទីឃាវុកុមារ ថ្វាយជីវិតព្រះអង្គហើយ លំដាប់នោះ ទីឃាវុកុមារបានពោលគាថា ដូច្នេះថា ៖

ជាញ្ញំ សុចរិតំ រាជ ជាញ្ញំ រាជ សុភាសិតំ
តាយតេ មរណកាលេ ឯវមេវិតរំ ធនំ ។

ញបពិត្រព្រះរាជា អ្វីដទៃក្រៅពីសុចរិត និងវាចាដែលជាសុភាសិត គឺមិនអាចការពារព្រះជន្មរបស់ព្រះអង្គ កុំឲ្យដល់ នូវមរណៈក្នុងពេលនេះបានឡើយ ទ្រព្យក្រៅពីនេះ ក៏យ៉ាងនោះដែរ ។

**អធិប្បាយថា** បពិត្រព្រះរាជា វៀរចាកសុចរិត និងវាចាជាសុភាសិត ពោលគឺឱវាទរបស់ព្រះបិតាទូលបង្គំចេញ ហើយ អ្វីដទៃអាចការពារក្នុងវេលាអស់ព្រះជន្ម រមែងមិនមានឡើយ ទ្រព្យក្រៅពីនេះក៏ដូចគ្នាដែរ គឺមិនមាន ប្រយោជន៍ទេ ព្រោះថាក្នុងពេលនេះ ទោះជាព្រះអង្គឲ្យទ្រព្យរាប់សែនកោដិ ដល់ទូលព្រះបង្គំ ក៏ព្រះអង្គមិនអាច បាននូវជីវិតដែរ ។

ព្រះបរមពោធិសត្វបានសម្ដែងព្រះគាថាជាបន្ត ៖

អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។

បុគ្គលទាំងឡាយណា ចងនូវពៀរនោះ ដោយគិតថា អ្នកឯណោះ បានជេរអញ បានវាយអញ បានផ្ចាញ់អញ បាន លួចយកទ្រព្យរបស់អញដូច្នេះ ពៀររបស់បុគ្គលទាំងឡាយនោះ រមែងមិនរំងាប់ឡើយ ។

អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។

បុគ្គលទាំងឡាយណា មិនចងនូវពៀរនោះថា អ្នកឯណោះ បានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួច យកទ្រព្យរបស់អញ ដូច្នេះ ពៀររបស់បុគ្គលទាំងឡាយនោះ ទើបរំងាប់បាន ។

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ
អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

ពៀរទាំងឡាយ ក្នុងលោកនេះ រមែងមិនរំងាប់ដោយពៀរទេ ពៀរទាំងឡាយ រមែងរំងាប់បានដោយការមិនមានពៀរ នេះជាបុរាណធម៌ ។

គ្រានោះស្ដេចក្នុងដែនកាសី និងទីឃាវុកុមារ បានឲ្យជីវិតគ្នាទៅវិញទៅមក បានចាប់ដៃគ្នាផង ធ្វើសម្បថផង ដើម្បីមិនឲ្យមានរឿងប្រទូសគ្នាតទៅទៀត ។ បន្ទាប់ពីត្រឡប់ចូលក្រុងវិញហើយ ព្រះរាជាបានប្រកាសឲ្យមនុស្ស ទាំងឡាយបានដឹងថា នេះជាកូនស្ដេចក្នុងដែនកោសល ឈ្មោះទីឃាវុកុមារ អ្នកទាំងឡាយ មិនត្រូវធ្វើទោស ចំពោះទីឃាវុកុមារនេះឡើយ ព្រោះទីឃាវុកុមារបានឲ្យជីវិតយើង ទាំងយើងក៏បានឲ្យជីវិតដល់ទីឃាវុកុមារវិញដែរ ។ ប្រកាសហើយ ព្រះរាជាបានសួរទៅទីឃាវុកុមារយ៉ាងនេះថា នៃទីឃាវុកូន ! កាលដែលព្រះបិតារបស់អ្នក ជិតនឹងធ្វើមរណភាព បានផ្ដាំបណ្ដាំណាចំពោះអ្នកថា ចូរកូនកុំឃើញកាលវែង កុំឃើញកាលខ្លី ធម្មតាពៀរមិន ដែលរំងាប់ដោយការចងពៀរទេ គឺពៀរតែងរំងាប់ដោយការមិនចងពៀរ តើបណ្ដាំនោះព្រះបិតារបស់អ្នកសំដៅ យកហេតុត្រង់ណា បានជាផ្ដាំដូច្នេះ ? ទីឃាវុកុមារ បានក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស កាលដែលព្រះ បិតារបស់ទូលព្រះបង្គំ ជិតនឹងធ្វើមរណភាព បានផ្ដាំបណ្ដាំណាចំពោះទូលព្រះបង្គំថា ចូរកូនកុំឃើញកាលវែង គឺកុំធ្វើពៀរឲ្យយូរអង្វែងឡើយ ឯបណ្ដាំដែលថា កុំឃើញកាលខ្លី គឺកុំប្រញាប់បែកចាកពួកមិត្តសម្លាញ់ឡើយ ។ សូម ទ្រង់ព្រះមេត្តាប្រោស ចំណែកបណ្ដាំបន្តមកទៀតថា ធម្មតាពៀរមិនដែលរំងាប់ដោយការចងពៀរទេ គឺពៀរតែងរំងាប់ដោយការមិនចងពៀរ នោះសំដៅត្រង់មាតាបិតារបស់ទូលព្រះបង្គំ ដែលទ្រង់ឲ្យគេប្រហារជីវិតហើយ ព្រោះ ហេតុនោះ ប្រសិនបើទូលព្រះបង្គំនឹងបំផ្លាញព្រះអង្គឲ្យដាច់ចាកជីវិតវិញ គង់មានពួកជនដែលប្រាថ្នាប្រយោជន៍ ចំពោះព្រះអង្គ នឹងបំផ្លាញទូលព្រះបង្គំឲ្យដាក់ចាកជីវិតវិញដែរ ហើយតទៅទៀត

ពួកជនដែលប្រាថ្នានូវ ប្រយោជន៍ដល់ទូលព្រះបង្គំ មុខតែបំផ្លាញពួកជនទាំងនោះឲ្យដាច់ចាកជីវិតមិនខានឡើយ ពៀរនោះមិនបាន រំងាប់ដោយការចងពៀរយ៉ាងនេះឯង ។ ឥឡូវព្រះអង្គទ្រង់ប្រទានជីវិតដល់ទូលព្រះបង្គំជាខ្ញុំហើយ ឯខ្ញុំព្រះអង្គក៏ បានថ្វាយជីវិតដល់ព្រះអង្គវិញដែរ ដូច្នោះ ពៀរនោះនឹងរំងាប់ដោយការមិនចងពៀរយ៉ាងនេះឯង សូមព្រះអង្គ ទ្រង់ជ្រាប ។ គ្រានោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់ស្ញើចថា អើហ្ន៎ ! ហេតុនេះហៅពេញជាអស្ចារ្យ ណាស់ អើហ្ន៎ ! ហេតុនេះហៅពេញជាចម្លែកណាស់ ទីឃាវុកុមារនេះពេញជាអ្នកប្រាជ្ញមែន ព្រោះដឹងសេចក្តីដែល បិតាពោលដោយសង្ខេបដោយពិស្តារបាន ។ ព្រះរាជាបានប្រគល់ពល ពាហនៈ ជនបទ ឃ្លាំង និងជង្រុក ជាកេរ ដំណែលបិតាទៅទីឃាវុកុមារវិញ ព្រមទាំងប្រទានធីតារបស់ព្រះអង្គទៀតផង ឲ្យទីឃាវុកុមារតាំងនៅក្នុង រាជសម្បត្តិគ្រប់គ្រងដែនកោសល ។ តាំងតែពីពេលនោះមក ព្រះរាជាទាំងពីរព្រះអង្គទ្រង់ស្ម័គ្រស្មាគម រីករាយ ព្រះហឫទ័យគ្រងរាជសម្បត្តិ ។

ព្រះបរមសាស្តា ទ្រង់ត្រាស់សម្តែងនូវរឿងនេះហើយ ព្រះភគវាព្រះអង្គទ្រង់ប្រទាននូវឱវាទដូច្នេះថា ម្នាលភិក្ខុ ទាំងឡាយ គួរកោតដែរ យ៉ាងពួកក្សត្រទាំងនោះ ធ្លាប់តែកាន់ដំបង កាន់គ្រឿងសស្ត្រាហើយមកចេះមានអំណត់ ព្រមទាំងប្រព្រឹត្តល្អបែបនេះបាន ។ ព្រោះហេតុដូច្នោះ ម្នាលភិក្ខុទាំងឡាយ ម្នាលអ្នករាល់គ្នាបានមកបួសក្នុង ធម្មវិន័យនេះ ដែលតថាគតបានសម្តែងដោយល្អយ៉ាងនេះហើយ គួរតែអត់ធន់ គួរតែខំប្រព្រឹត្តល្អ ឲ្យល្អឡើង ។

ញព្រះបរមសាស្តា ទ្រង់ប្រជុំជាតកថា មាតាបិតាក្នុងគ្រានោះ បានមកជាត្រកូលមហារាជ ចំណែកទីឃាវុកុមារ បាន មកជា **តថាគត** ដូច្នេះឯង ៕

Source: https://aphirati.wordpress.com/category/និទានជាតក/


***Website: BVDCC.org***

***E-mail: Chhenchhoun@gmail.com***

***YouTube: Vipassana Dhurak Buddhist Centre***

***YouTube: ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា***

**ពុទ្ធមណ្ឌលវិបស្សនាធុរៈ**
**នៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# តិលមុដ្ឋិជាតក

## គប្បីហាមឃាត់អំពើអាក្រក់ តាំងពីនៅតិចតួច

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ទ្រង់ប្រារព្ធភិក្ខុមួយ អង្គដែល ច្រើនទៅដោយសេចក្តីក្រោធ ទើបត្រាស់រឿងនេះ មានព្រះបាលីថា **អជ្ជាបិ មេ តំ មនសិ** ដូច្នេះជាដើម ។

បានស្តាប់មកថា មានព្រះភិក្ខុ ១ អង្គ លោកច្រើនទៅដោយសេចក្តីក្រោធ និងសេចក្តីចង្អៀតចង្អល់ចិត្ត គ្រាន់តែអ្នកដទៃថាអ្វីឲ្យបន្តិចបន្តួច ក៏ខឹងក្រោធភ្លាម ធ្វើការប្រទូសរ៉ាយ និងការអន់ចិត្តឲ្យប្រាកដ ។ ក្រោយមកថ្ងៃមួយ ភិក្ខុទាំងឡាយគង់អង្គុយសន្ទនាគ្នាក្នុងសាលាធម្មសភាថា លោកដ៏មានអាយុទាំង ឡាយ ភិក្ខុអង្គនោះ ជាបុគ្គលច្រើនដោយសេចក្តីក្រោធ និងសេចក្តីចង្អៀតចង្អល់ចិត្ត ពេលក្រោធម្តងៗ មានសភាពដូចអំបិលដែលគេបាចក្នុងភ្លើងចង្ក្រាន ដូច្នោះឯង ។ លោកបួសក្នុងព្រះសាសនា ដែល ប្រដៅមិនឲ្យក្រោធ ជាសាសនានាំសត្វឲ្យរួចផុតចាកពីសេចក្តីសៅហ្មងគ្រប់យ៉ាង ប៉ុន្តែសូម្បីគ្រាន់តែ សេចក្តីក្រោធប៉ុណ្ណោះ ក៏មិនអាចគ្របសង្កត់បាន។ ព្រះបរមសាស្តាស្តេចយាងមកកាន់សាលាធម្មសភា ទ្រង់ជ្រាបអំពីការសន្ទនារបស់ភិក្ខុទាំងឡាយ ព្រះអង្គត្រាស់ឲ្យភិក្ខុ ១ អង្គទៅនិមន្តភិក្ខុដែលច្រើនទៅ ដោយសេចក្តីក្រោធនោះមក កាលដែលលោកនិមន្តមកដល់ហើយ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ មានដំណឹងថា លោកជាបុគ្គលក្រោធងាយ ពិតមែនឬ ? កាលដែលភិក្ខុអង្គនោះ ក្រាបទូលការពិតហើយ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ភិក្ខុនេះក៏បានជាអ្នកច្រើនទៅដោយសេចក្តីក្រោធដូចគ្នាដែរ។ កាលដែលភិក្ខុទាំងឡាយទូលអារាធនា ទើបព្រះភគវា នាំយករឿងក្នុងអតីតកាលមកសម្តែងតទៅ ៖

ក្នុងអតីតកាល គ្រាដែលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ឱរសរបស់ព្រះបាទ ព្រហ្មទត្តនោះ មាននាមថា ព្រហ្មទត្តកុមារ។ ក្នុងការអប់រំនិងបណ្តុះបណ្តាលបុត្រ ព្រះរាជាក្នុងគ្រាមុនៗ សូម្បីមានអាចារ្យទិសា-បាមោក្ខក្នុងនគររបស់ខ្លួនក៏ដោយ ក៏នៅតែបញ្ជូនបុត្ររបស់ព្រះអង្គឲ្យទៅរៀនសិល្បសាស្ត្រនៅទីឆ្ងាយ ក្រៅពីនគររបស់ខ្លួនដែរ ។ ដែលធ្វើយ៉ាងនេះ មកអំពីព្រះរាជាមានសេចក្តីសង្ឃឹមថា ព្រះរាជបុត្រទាំងនោះ នឹងកម្ចាត់នូវភាពក្រអឺតក្រអោងដោយមានៈផង និងជាអ្នកចេះមានសេចក្តីអត់ធន់ចំពោះក្តៅរងាផង ព្រមទាំងនឹងបានដឹងនូវប្រពៃណី ទំនៀមទម្លាប់របស់មនុស្ស ក្នុងលោកផងដែរ ។ ព្រោះហេតុដូច្នោះ ទើបព្រះបាទព្រហ្មទត្ត ត្រាស់ហៅព្រហ្មទត្តកុមារជាព្រះរាជបុត្រ ដែលមាន

ព្រះជន្មវស្សា ១៦ ឆ្នាំ ឲ្យចូលមកគាល់ ហើយព្រះរាជទាននូវស្បែកព្រះបាទមួយគូ ឆត្រស្លឹកឈើមួយ និងទ្រព្យ ១ ពាន់កហាបណៈ ព្រមទាំងត្រាស់ប្រាប់ថា បុត្រចូរទៅកាន់នគរតក្កសិលា ប្រឹងប្រែងសិក្សាយកនូវសិល្បសាស្ត្រមក ។ ព្រហ្មទត្តកុមារទទួលព្រះរាជឱង្ការហើយថ្វាយបង្គំព្រះរាជមាតាបិតាលាចេញទៅ ។ ព្រហ្មទត្តកុមារ ក៏បានសួររកផ្ទះលោកអាចារ្យឃើញហើយ ក៏ដោះស្បែកព្រះបាទ និងដោះឆត្រ ចូលទៅសំពះលោកអាចារ្យ រួចឈរក្នុងទីដ៏សមគួរ ។ កាលដែលលោកអាចារ្យធ្វើបដិសណ្ឋារៈ និងសាកសួរដឹងហេតុការណ៍សព្វគ្រប់ហើយ ក៏ទទួលបង្ហាត់បង្រៀននូវសិល្បសាស្ត្រដល់ព្រហ្មទត្តកុមារដោយពិស្តារ ចំណែកព្រះរាជកុមារ ក៏រៀនយកនូវសិល្បសាស្ត្រដោយការតាំងចិត្ត ។

ថ្ងៃមួយ ព្រហ្មទត្តកុមារ និងសិស្សទាំងឡាយ ទៅងូតទឹកព្រមជាមួយនឹងលោកអាចារ្យ គ្រានោះមានស្ត្រីចាស់ជរាម្នាក់បកសំបកគ្រាប់ល្ងហើយយកមកហាល ទាំងដែលនៅអង្គុយចាំមើលទៀតផង ព្រហ្មទត្តកុមារ ឃើញគ្រាប់ល្ងដែលយាយហាល ក៏នឹកចង់បរិភោគ ទើបចាប់យកមួយក្ដាប់ដៃមកទំពាបរិភោគ ស្ត្រីចាស់ជរាគិតថា មាណពនេះចង់បរិភោគ ទើបអង្គុយស្ងៀមមិនបានពោលអ្វីឡើយ ។ ថ្ងៃបន្ទាប់មកទៀត ព្រះរាជកុមារនោះ ក៏បានធ្វើយ៉ាងនោះទៀត សូម្បីស្ត្រីចាស់ជរាក៏មិនបានពោលថាអ្វីដែរនៅស្ងៀមជាលើកទី ២ ។ លុះដល់ថ្ងៃទី ៣ ព្រះរាជកុមារក៏នៅតែចាប់យកល្ងរបស់ស្ត្រីចាស់ជរានោះដដែលទៀត លើកនេះ ស្ត្រីចាស់ជរាមិនអាចទ្រាំបាន គាត់ស្រែកយំហើយពោលរៀបរាប់ថា អាចារ្យទិសាបាមោក្ខ ប្រើឲ្យសិស្សរបស់ខ្លួនប្លន់យើង ។ អាចារ្យត្រឡប់មកសួរថា តើមានរឿងអ្វីលោកយាយ ។ ស្ត្រីចាស់ជរាពោលថា លោកអាចារ្យ សិស្សរបស់លោកបរិភោគគ្រាប់ល្ងខ្ញុំថ្ងៃនេះមួយក្ដាប់ ម្សិលមិញមួយក្ដាប់ ម្សិលម៉្ងៃមួយក្ដាប់ បើសិស្សលោកអាចារ្យ ស៊ីល្ងរបស់ខ្ញុំយ៉ាងនេះ ទោះជាគ្រាប់ល្ងរបស់ខ្ញុំមានប៉ុន្មានក៏មិនសល់ដែរ ។ អាចារ្យទិសាបាមោក្ខពោលថា សូមលោកយាយ ឈប់យំទៅណ៎ា! ចាំខ្ញុំសងតម្លៃល្ងដល់លោកយាយ ។ ស្ត្រីចាស់ជរាពោលថា ខ្ញុំមិនត្រូវការតម្លៃអ្វីទេ ខ្ញុំត្រូវការឲ្យលោកប្រដៅសិស្សរបស់លោក កុំឲ្យថ្ងៃក្រោយធ្វើអីចឹងទៀត ។ អាចារ្យពោលថា មិនអីទេលោកយាយ សូមលោក យាយកុំព្រួយ លោកយាយចាំមើលណ៎ា! ភ្លាមនោះ លោកអាចារ្យបានឲ្យមាណពពីរនាក់ ចាប់ដៃព្រះរាជកុមារម្ខាងម្នាក់ ហើយទើបយកសំពត់ឫស្សីមកវាយកណ្ដាលខ្នងព្រះរាជកុមារ ៣ រំពាត់ ព្រមទាំង ពោលប្រដៅថា អ្នកកុំធ្វើយ៉ាងនេះតទៅទៀត ។ ព្រះរាជកុមារក្រោធចំពោះលោកអាចារ្យ មានភ្នែកក្រហមសម្លឹងមើលលោកអាចារ្យតាំងពីខ្នងជើងរហូតដល់ចុងសក់ ។

ព្រះរាជកុមារ ប្រឹងប្រែងរៀនសិល្បសាស្ត្ររហូតដល់ចប់ ទាំងមានគំនុំទុកក្នុងហឫទ័យ ដោយចងអាឃាតថា យើងនឹងសម្លាប់អាចារ្យនេះ នៅពេលដែលយើងបានសោយរាជ្យ ។ ដល់ពេលដែលត្រូវចាកចេញទៅកាន់ព្រះនគរវិញ ព្រះរាជកុមារបានក្រាបសំពះលោកអាចារ្យ ធ្វើដូចជាមានសេចក្ដីស្រឡាញ់និងដឹងគុណគ្រូអាចារ្យណាស់ បានពោលផ្ដាំថា បពិត្រលោកអាចារ្យ កាលណាដែលខ្ញុំបាននូវរាជសម្បត្តិក្នុងព្រះនគរពារាណសី ខ្ញុំនឹងបញ្ជូនដំណឹងមក កាលនោះសូមលោកអាចារ្យអញ្ជើញទៅ កុំខានឲ្យសោះ ពោលផ្ដាំរួចហើយក៏ចាកចេញទៅ ។

ព្រហ្មទត្តកុមារ ធ្វើដំណើរដល់ក្រុងពារាណសី បានចូលទៅថ្វាយបង្គំព្រះជនកព្រះជននី ហើយសម្តែងសិល្បសាស្ត្រឲ្យទ្រង់ទាំងពីរបានទតព្រះនេត្រ ។ ព្រះរាជាត្រាស់ថា យើងមានជីវិតនៅទាន់បុត្ររបស់យើងហ្ន៎ ! ដែលបុត្ររបស់យើងរុងរឿងក្នុងរាជសម្បត្តិ ទើបទ្រង់ស្ថាបនាព្រះរាជបុត្រ ឲ្យជាព្រះរាជាគ្រប់គ្រងព្រះនគរតទៅ ។ កាលបានគ្រងសិរីរាជសម្បត្តិហើយ ក៏រលឹកដល់រឿងដែលលោកអាចារ្យបានធ្វើមកលើព្រះអង្គ កាលដែលទ្រង់នៅជាសិស្សក្នុងនគរតក្កសិលា ស្តេចទ្រង់វិរោធឆួលឆេះក្នុងព្រះឱរា ទើបចាត់ការបញ្ជូនទូតទៅ ដោយតាំងព្រះហឫទ័យថា យើងនឹងសម្លាប់អាចារ្យនោះ ។ លោកគ្រូអាចារ្យបានទទួលការអញ្ជើញពីព្រះរាជាក្រុងពារាណសីហើយ ក៏គិតថា ក្នុងពេលដែលព្រះរាជានៅក្មេង ដូច្នេះយើងមិនអាចឲ្យទ្រង់យល់បានឡើយ គិតហើយ គាត់ក៏មិនបានទៅក្នុងពេលនោះដែរ ។ លុះដល់វេលាដែលព្រះរាជានោះ ចូលដល់មជ្ឈិមវ័យហើយ ទើបលោកគ្រូអាចារ្យគិតថា ឥឡូវនេះ យើងអាចធ្វើឲ្យព្រះរាជាក្រុងពារាណសីយល់បាន ទើបធ្វើដំណើររហូតចូលដល់ក្រុងពារាណសី ហើយឈរនៅនាខ្លោងទ្វារព្រះរាជវាំង ឲ្យគេក្រាបទូលថា អាចារ្យពីនគរតក្កសិលាមកហើយ ។ ព្រះរាជាទ្រង់សោមនស្សត្រេកអរបង្គាប់ឲ្យនាំលោកគ្រូអាចារ្យចូលមក គ្រាន់តែទ្រង់ទតព្រះនេត្រឃើញលោកគ្រូអាចារ្យដែលចូលមកគាល់ភ្លាម ទ្រង់ពិរោធរហូតដល់ព្រះនេត្រទាំងពីរឡើងក្រហម ហើយត្រាស់ហៅអាមាត្យទាំងឡាយមកថា នែអាមាត្យទាំងឡាយ ! អាចារ្យនេះហើយវាយយើងឲ្យបែកខ្នង នៅស្នាមរហូតដល់សព្វថ្ងៃ ឥឡូវគេមករកសេចក្តីស្លាប់ដោយមិនដឹងខ្លួនថា អាត្មាអញ នឹងស្លាប់ក្នុងថ្ងៃនេះ ។ រួចហើយព្រះរាជាបានត្រាស់ទៅរកលោកគ្រូអាចារ្យ ដោយគាថា ដែលមានសេចក្តីថា

អ្នកឲ្យគេចាប់យើងត្រង់ដើមដៃ ហើយអ្នកវាយយើងដោយរំពាត់ ព្រោះហេតុតែល្ងមួយក្តាប់ ការវាយយើងដោយរំពាត់ ព្រោះហេតុតែល្ងមួយក្តាប់ ការវាយនោះ ប្រាកដក្នុងចិត្តរបស់យើងដរាបដល់ថ្ងៃនេះ។

ម្នាលព្រាហ្មណ៍ អ្នកមិនត្រេកអរក្នុងជីវិតរបស់អ្នកហើយឬ ទើបបានជាមករកយើងដល់ទីនេះ អំពើដែលអ្នកឲ្យគេចាប់ដៃយើងម្ខាងម្នាក់ ហើយអ្នកបានវាយយើងដល់ទៅ ៣ រំពាត់នោះ នឹងតបស្នងដល់អ្នកវិញក្នុងថ្ងៃនេះឯង ។

លោកគ្រូអាចារ្យបានស្តាប់ហើយ ទើបពោលគាថា ដូច្នេះថា ៖

អរិយោ អនរិយំ កុព្វំ យោ ទណ្ឌេន និសេធតិ
សាសនំ តំ ន តំ វេរំ ឥតិ នំ បណ្ឌិតា វិទូ ។

អរិយជនណា ហាមឃាត់នូវបុគ្គលមិនប្រសើរ មានការដាក់ទោសដល់អ្នកដែលប្រព្រឹត្តអាក្រក់ អំពើរបស់អរិយជននោះ រាប់ថាជាការប្រៀនប្រដៅ គឺមិនមែនជាពៀរឡើយ បណ្ឌិតទាំងឡាយ រមែងដឹងច្បាស់នូវហេតុនោះ ដូច្នេះឯង ។

បពិត្រមហារាជ ព្រោះហេតុនោះ សូម្បីព្រះអង្គក៏សូមទ្រង់ជ្រាបយ៉ាងនេះចុះ ព្រះអង្គមិនគួរសាងកម្មពៀរក្នុងសភាពបែបនេះឡើយ ។ ប្រសិនបើក្នុងកាលនោះ ទូលព្រះបង្គំ មិនបានទូន្មានប្រៀនប្រដៅ

ព្រះអង្គទេ បន្តមកទៀត ទ្រង់នឹងលួចនំ លួចស្ករក្រួសនិងផ្លែឈើជាដើម ម្ល៉ោះហើយទ្រង់នឹងធ្លាក់ក្នុងចោរកម្មផ្សេងៗ រហូតដល់លួចប្លន់សម្លាប់មនុស្សតាមផ្លូវ សម្លាប់អ្នកស្រុកទីបំផុត ត្រូវគេចាប់បានព្រមទាំងព័ស្តុតាងទូលដល់ព្រះរាជា ទ្រង់នឹងទទួលនូវភ័យគឺអាជ្ញា ដោយព្រះតម្រាស់ថា ពួកអ្នកចូរដាក់អាជ្ញាឲ្យសមគួរដល់ទោសរបស់ចោរនេះ ដូច្នោះ តើសម្បត្តិមានសភាពបែបនេះ នឹងសម្រេចដល់ព្រះអង្គបានដូចម្តេចទៅ តាមពិត ទ្រង់បានដល់នូវសភាពជាធំយ៉ាងរៀបរយដូច្នេះ ក៏ព្រោះអាស្រ័យទូលព្រះបង្គំជាខ្ញុំហ្នឹងឯង មិនមែនទេឬ ? លោកគ្រូអាចារ្យបានធ្វើឲ្យព្រះរាជាទទួលព្រមដោយប្រការដូចពោលមកនេះឯង ។

ក្នុងពេលនោះ អាមាត្យទាំងឡាយ ដែលឈរនៅជុំវិញ បានស្តាប់ពាក្យលោកគ្រូអាចារ្យហើយទើបក្រាបទូលថា ព្រះករុណាថ្ងៃវិសេស ពាក្យដែលលោកអាចារ្យពោលនេះជាការពិតណាស់ ភាពជាធំនេះ គឺជារបស់លោកអាចារ្យរបស់ព្រះអង្គដោយពិត ។ ខណៈនោះ ព្រះរាជាទ្រង់កំណត់បាន ទ្រង់ដឹងគុណលោកគ្រូអាចារ្យទើបត្រាស់ថា បពិត្រលោកអាចារ្យ ខ្ញុំសូមជូននូវភាពជាធំនេះដល់លោក សូមលោកទទួលនូវរាជសម្បត្តិនេះចុះ ។ លោកគ្រូអាចារ្យបដិសេធថា ទូលព្រះបង្គំជាខ្ញុំមិនត្រូវការនូវរាជសម្បត្តិឡើយ ។ ព្រះរាជាទ្រង់បានបញ្ជូនដំណឹងទៅកាន់នគរតក្កសិលា ឲ្យនាំបុត្រនិងភរិយារបស់លោកគ្រូអាចារ្យមក ហើយទ្រង់ប្រទានឥស្សរិយយសដ៏ធំ ដោយទ្រង់តែងតាំងលោកគ្រូអាចារ្យនោះឯង ក្នុងតំណែងជាបុរោហិត និងតាំងទុកក្នុងឋានៈជាបិតា ។ ព្រះរាជាតាំងនៅក្នុងឱវាទរបស់បុរោហិត បំពេញបុណ្យទាំងឡាយមានទានជាដើម និងមានសុគតិភពប្រព្រឹត្តទៅខាងមុខ ។

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់នាំយកនូវព្រះធម៌ទេសនានេះ មកសម្តែងរួចហើយ ព្រះអង្គទ្រង់ប្រកាសចតុរារិយសច្ច និងប្រជុំជាតក ។ ក្នុងវេលាចប់សច្ចកថា ភិក្ខុដែលច្រើនទៅដោយសេចក្តីក្រោធ បានតាំងនៅក្នុងអនាគាមិផល បរិស័ទដទៃៗ បានជាព្រះសោតាបន្ន និងព្រះសកទាគាមី ។ ព្រះរាជាក្នុងគ្រានោះ បានមកជាភិក្ខុដែលច្រើនទៅដោយសេចក្តីក្រោធនេះឯង ចំណែកលោកគ្រូអាចារ្យគឺបានមកជា **តថាគត** ៕

Source: https://aphirati.wordpress.com/category/និទានជាតក/

***Website: BVDCC.org***

***E-mail: [Chhenchhoun@gmail.com](mailto:Chhenchhoun@gmail.com)***

***YouTube: Vipassana Dhurak Buddhist Centre***

***YouTube: ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា***